**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០១ សរ**

# សារាចរ

## ស្តីពី

## ការកំណត់នីតិវិធីសម្រាប់បើកផ្តល់ប្រាក់របបសន្តិសុខសង្គមរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក

ដើម្បីការធានាបើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក តាមរយៈបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស.) និងបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) បានឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែ នីមួយៗ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម ៖

**១ - ការរៀបចំតារាងបើកប្រាក់របបសន្តិសុខសង្គម នៃខែនីមួយៗ**

ប.ជ.ស. និង ប.ជ.អ. ត្រូវគ្រប់គ្រងការបញ្ចូល ការផ្លាស់ប្តូរស្ថានភាព និងការលុបសិទ្ធិវន្តរបស់ខ្លួននៅរៀងរាល់មុនដំណាច់សប្តាហ៍ទី៣នៃខែនីមួយៗ ដើម្បីរៀបចំតារាងបើកប្រាក់របបសន្តិសុខសង្គម។ ប.ជ.ស. និង ប.ជ.អ. ត្រូវរៀបចំការណែនាំលម្អិតអំពីនីតិវិធី ទម្រង់បែបបទ និងឯកសារតម្រូវក្នុងការគ្រប់គ្រង ការបញ្ចូល ការផ្លាស់ប្តូរស្ថានភាព និងការលុបសិទ្ធិវន្ត ដល់អង្គភាពចំណុះ ដោយសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត។

**២ - ការរៀបចំអាណត្តិបើកប្រាក់របបសន្តិសុខសង្គម**

ប.ជ.ស. និង ប.ជ.អ. ត្រូវរៀបចំអាណត្តិបើកប្រាក់របបសន្តិសុខសង្គម ដោយផ្អែកលើតារាងទូទាត់ប្រាក់របបសន្តិសុខសង្គមប្រចាំខែ និងត្រូវបើកផ្តល់ប្រាក់របបសន្តិសុខសង្គមនៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ។

**៣ - ការពិនិត្យ និងចុះហត្ថលេខាលើអាណត្តិបើកប្រាក់របបសន្តិសុខសង្គម**

- អាណត្តិបើកប្រាក់របបសន្តិសុខសង្គម ដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ក និងទទួលបានទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋាន រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១នៃខែ ដែលត្រូវបើកផ្តល់ប្រាក់ របបសន្តិសុខសង្គម

- ក្នុងករណីពុំទាន់មានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំនៅក្រសួង ស្ថាប័ន អាណត្តិបើកប្រាក់របបសន្តិសុខសង្គម ដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ករួចហើយ ត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី១ ក្នុងសប្តាហ៍ទី១នៃខែ ដែលត្រូវបើកផ្តល់ប្រាក់របបសន្តិសុខសង្គម ដើម្បីទទួលបាន ទិដ្ឋាការ រួចត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិយ៉ាងយូរត្រឹមថ្ងៃទី៤ ក្នុងសប្តាហ៍ទី១ នៃខែ ដែលត្រូវបើក ផ្តល់ប្រាក់របបសន្តិសុខសង្គម។

**៤ - ការបើកផ្តល់ប្រាក់របបសន្តិសុខសង្គម**

- អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់ចែងការត្រួតពិនិត្យ និងរៀបចំបើក ផ្តល់ប្រាក់របបសន្តិសុខសង្គមដល់ ប.ជ.ស. និង ប.ជ.អ. ឲ្យបានទាន់ពេលវេលានៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុង ខែនីមួយៗក្នុងនោះ ៖

លើកទី១ឲ្យបានទាន់ក្នុងសប្តាហ៍ទី២ និងលើកទី២ឲ្យបានទាន់ក្នុងសប្តាហ៍ទី៤ បន្ទាប់ពីទទួល បានអាណត្តិបើកប្រាក់របបសន្តិសុខសង្គមពី ប.ជ.ស. និង ប.ជ.អ. តាមកាលកំណត់ខាងលើ

- ក្នុងករណី ប.ជ.ស. និង ប.ជ.អ. មិនបានបញ្ជូនអាណត្តិបើកប្រាក់របបសន្តិសុខសង្គមតាមកាលកំណត់ខាងលើ អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់ចែងបើកផ្តល់ប្រាក់របបសន្តិសុខសង្គមដល់ ប.ជ.ស. និង ប.ជ.អ. ដោយធ្វើការបុរេប្រទានសាច់ប្រាក់ផ្អែកលើតារាងទូទាត់ប្រាក់របបសន្តិសុខសង្គមនៃសប្តាហ៍ កន្លងទៅដែលផ្តល់ដោយ ប.ជ.ស. និង ប.ជ.អ. ឲ្យបានទាន់ពេលវេលាកំណត់ ដោយចាត់ទុកថា ប.ជ.ស. និង ប.ជ.អ. បានឯកភាពជាស្វ័យប្រវត្តិលើការទូទាត់បើកផ្តល់ប្រាក់របបសន្តិសុខសង្គមនោះ ប៉ុន្តែ ប.ជ.ស. និង ប.ជ.អ. ត្រូវធ្វើការ ទូទាត់ជម្រះបញ្ជីបុរេប្រទាននោះតាមក្រោយ ស្របតាមនីតិវិធីហិរញ្ញវត្ថុ

- ប.ជ.ស. និង ប.ជ.អ. ត្រូវចេញសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទ នៃការបើកប្រាក់របបសន្តិសុខសង្គមជូនអតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក។

**៥ - គណនេយ្យភាព និងការទទួលខុសត្រូវ**

- អាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនឹងអាណត្តិបើកប្រាក់របប សន្តិសុខសង្គម ដូចដែលបានរៀបរាប់ខាងលើ ត្រូវចាត់ចែងបំពេញភារកិច្ចឱ្យបានទាន់ពេលវេលាកំណត់។

- អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវអនុវត្តភារកិច្ចតាមខ្លឹមសារ នៃសារាចរនេះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្អែកតាមកម្រិតឋានានុក្រម ព្រមទាំងត្រូវទទួលខុសត្រូវផ្សេងទៀត ជាយថាហេតុផ្អែកតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

បានទទួលសារាចរណែនាំនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តឲ្យមានប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១១ រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា*
- *គ្រប់សាលារាជធានី ខេត្ត*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*